Charlie



Charlie Chaplin is alive and well in Cambodia. Chaplin visited Phnom Penh in 1936, arriving with Paulette Goddard overland by car. As they toured the city, Indochinese newspapers had a field day. Following this single visit 66 years ago, Chaplin has remained part of Cambodian popular culture. Today, stand-up comics in Phnom Penh still emulate his mustachioed, black-eyed, baggy trousered image.

Darryl Collins *explains the fascination.*

Chaplin *in Cambodia*

Charlie Chaplin's legacy lives on in Cambodia. Many comedians (**above and page 18**) still model their dress, mime and manner on him.

In March 1936, excited rumours fuelled by reports from Singapore began circulating through the Indochina press based in Saigon. It now seemed a certainty that one of the most famous stars in motion-picture history, Charles Chaplin (1889-1977), better known throughout Indochina by his French name "Charlot", was to visit Cambodia!

Chaplin had continued his great role of the Tramp in his first two sound films for United Artists Corporation, *City Lights* (1931) and *Modern Times* (1936). It was in the latter film that Chaplin aimed his satyric wit at the new machine age by dabbling in Marxian themes of man versus machine. *Les Temps Modernes* was to be his last "silent" film – silent only in its lack of speech, for Chaplin composed the music and added special sound effects.

On 12 February 1936, five days after the première of *Modern Times* at Grauman's Chinese Theatre in Hollywood, Chaplin and his party sailed from the United States on the *SS President Coolidge* for a trip to Hawaii and ports on the Asia-Pacific rim. Paulette Goddard, his dazzling co-star in *Modern Times*, accompanied him on the five-month voyage. A wire report soon after their departure informed the world that Charlie and Paulette had been married in Singapore (other sources said Canton), although years later in his autobiography Chaplin would only confirm they were married in the Orient, leaving the location unidentified by name. Goddard had been Chaplin's resident mistress at his Summit Drive Beverly Hills California mansion since 1932, but, inexplicably all members of the party were listed on the ship's passenger list as residing at 1103 Coneway Avenue, Beverly Hills.

Quoted in the press of the day as being 21 years old, Goddard was in fact more likely some 25 years of age. One inquisitive Indochina reporter immediately inquired of the starlet about the latest "big news". Had Miss Goddard become Mrs Charlie Chaplin or not? Her reply was evasive. The pretty actress did not deny she had the right to wear a diamond and platinum wedding ring on her left third finger, but she claimed that this did not mean her husband was Charlie Chaplin. She cut short further questions by declaring that she was strongly opposed to discussing her private affairs in public.

Charlie Chaplin's party, comprising Goddard, her mother, and Frank Yonamori (a Japanese majordomo) sailed on the *Suwa Maru* – through the agency of Thos. Cook & Son – from Shanghai to Singapore, arriving on the 19th of March 1936. On the 22nd of March, they passed through the Malacca Straits, visited Bali and Java, and then returned to Singapore on the 3rd April. In Singapore, Chaplin stayed at the famous Raffles Hotel.

The travellers arrived in Saigon on the 12th of April aboard the vessel *Äramis*, then drove to Phnom

Penh, where they arrived at Hôtel Le Royal on the 18th. Upon the celebrities' arrival at Le Royal that Tuesday evening, reporters flocked to the hotel. Their visit to Phnom Penh was short – a mere 24 hours. On Wednesday morning the 19th, the party departed for Angkor. Members of the press, representing no less than five of Indochina's daily newspapers, covered Chaplin's movements and his impressions of Cambodia. Reporters noted that Chaplin received them with "much courtesy and charm" for interviews at the hotel. "We were not only simply to interview him, but able to have two hours of agreeable conversation with him around a bar table."

Badly informed in Saigon about what he would find during the Cambodian sector of his trip, it seems, Chaplin had arrived in Phnom Penh "expecting to camp in a broom closet". He found himself instead at Le Royal, where, in his words, one was "put up at a superb hotel where he enjoyed such perfect service."

What were his impressions of Phnom Penh? "The Cambodian capital is a charming little town. The Royal Palace as well as the Silver Pagoda are delightfully pretty." Captivated by the local lifestyle, he added, "the Cambodian houses are very picturesque." He had nothing but laudatory remarks for the older Cambodian (French) colonists, but had one sole criticism. Once again his comment was related to domestic architecture, more specifically the quasi-elegance of the European houses, which he was surprised to see built in the style of suburban villas exhibiting ("which one knows is open to question"), a general lack of comfort.

Earlier that same day Chaplin had visited the Silver Pagoda and the Royal Palace, where he was pleased to have seen His Majesty King Sisowath Monivong in this most appropriate of settings. He wandered through the city and was obviously impressed by what he saw. The media reported that Chaplin appreciated the scenes of local life and was taken by the liveliness evident during his stroll in the "Asiatic quarters", a reference perhaps, to the *Quartier Chinois* – the Chinese sector in the vicinity of the Grand March (Psah Thmei) which was then under construction.

Oddly enough, Chaplin explained with surprise, he found himself in a city where he considered certain reclaimed avenues, only recently laid over former canals, as being "little sisters" to the grand Champs Elysées in Paris.

Members of the press could not resist speculating on a possible movie based on his visit to Indochina:

> Without a doubt, one day we will be seeing on Indochina screens, a film inspired by the trip to Cambodia by the great mime artist. ...But we will nevertheless have to be patient as Charlie did not hide from us that he didn't plan to abandon the wise measure (that he has had for several years now) of limiting his film activity to one film every five years.

Unfortunately, this film never materialized. The reporters further speculated:

> In response to our question about whether he planned to profit from his stay in Indochina to take part in some great hunting, he simply told us that he had never fired a rifle in his life and felt no desire to kill. The only game that interested him was the elephant – which he only desired to capture and not to kill.

The great comedian concluded the evening interview with the observation that his drive through Indochina had been productive, in terms of new and unexpected sights. He offered his services to carry out intensive publicity on behalf of Indochina tourism on his return to the United States. The following morning, the party was driven to Siem Reap.



Victor Goloubew (1878-1945) – a wealthy aristocrat from St Petersburg, well connected in Parisian society (he knew the artist Auguste Rodin personally) and possessed of a taste for the fashionable life – was one of the archaeologists working at Angkor. It was in the scholarly role of École Française d'Extrême-Orient art historian that he hosted the party's April 1936 tour of the temples. As they had enjoyed their brief stay at Le Royal in Phnom Penh, the party almost certainly stayed at the Grand Hôtel d'Angkor while in Siem Reap. Following their visit to

the sites, the travellers returned to Saigon via Phnom Penh for the remainder of the Indochina tour that included the cities of Dalat, Hué and Hanoi.

When the alleged honeymooners returned to California in June 1936, Goddard played out her well-

rehearsed cat-and-mouse games with consummate skill – this time with American reporters.

"Are you and Mr Chaplin married?"

"It's never been announced officially."

"But is it so?" ... "Would you deny you are Mrs Chaplin?"

"I never discuss my private life. I find that my private life is one thing and my career another."

The enigma persists to this day, and the journalists' questions will in all probability remain unanswered. Did Goddard marry Chaplin in the East, or was it all simply a charade? Biographer Kenneth S. Lynn in his recent book *Charlie Chaplin and His Times* (1998) suggests that "the overwhelming likelihood is they had never been married, and that the divorce proceeding was undertaken at Goddard's insistence." Following several subsequent affairs, Chaplin married Oona O'Neill on 16 June 1943.

Postscript: It is now some 66 years since Charlie Chaplin ventured into Indochina. As evidenced by Phnom Penh movie advertisements of the '20s and '30s, he was incontestably popular. His fame continued undiminished. In the '50s, Huor In, a Chinese-run Phnom Penh business, displayed a sign stretching the full length of the shophouse promoting "Charlot Traditional Wine Medicine".

Charlie's image of the down-but-not-out tramp still flourishes throughout Cambodia. Today, video vendors at Psah Thmei (the New Market) offer compilations of Chaplin's most famous films. Currently, there are several popular Cambodian comedians – typically moustached with dark-ringed eyes and curly, slightly dishevelled hair – that model their attitudes of mime and manner on Chaplin. And the debt to Chaplin does not stop here. His pervasive presence is also found in the Lakhaon Bassac folkloric theatre, where young Cambodian performing arts students learn to apply the same makeup to recreate his facial character. This genre, strongly reminiscent of Chinese opera, incorporates diverse influences, including that of Vietnamese classical theatre, Khmer theatre and even Hindi and Western movies. One could add Charlie's name to this list, for he seems to have left an indelible impression on this theatre school.

In Cambodia, the legacy of "the little fellow" remains preserved so future generations may continue laughing at "the funniest man in the world". Contemporary Cambodian comedians Neay Krim, Neay Pek Kuork, Neay Laosy and Neay Lotto would have to agree!

*Chaplin was so impressed by his visit that he offered to carry out intense publicity on behalf of Indochina tourism on his return to the United States. (**Below**), a 1939 map of Indochina. Edited by the Official Tourist Bureau, Saigon 1939. Private collection, Phnom Penh.*



សាក់ឡូ

ឆាលី ឆាបលីន
ហៅ សាក់ឡូ
នៅក្នុងប្រទេសកម្ពុជា

នៅក្នុងខែ មីនា ឆ្នាំ ១៩៣៦ ពាក្យចរចាមអារ៉ាមលាយឡំជាមួយនឹងការរំភើប ដែលលេចលឺចេញមកពីសេចក្តីរាយការណ៍ពីប្រទេសសឹង្ហបុរី បានចាប់ផ្តើមល្បីខ្ចរខ្ចាយនៅក្នុងចំណោមសារពតិមានឥណ្ឌូចិន ដែលមានមូលដ្ឋាននៅក្នុងក្រុងហូជីមិញ ។ ឥឡូវនេះ វាហាក់បីដូចជាមានភាពច្បាស់លាស់ណាស់ថា តារាកំប្លែងដ៏ល្បីមួយរូបក្នុងចំណោមតារាកំប្លែងល្បីៗបំផុតនៅក្នុងប្រវត្តិសាស្ត្រភាពយន្ត គឺលោក ឆាលី ឆាបលីន (កើតឆ្នាំ ១៨៨៩ មរណភាពឆ្នាំ ១៩៧៧) ដែលគេស្គាល់ឈ្មោះជាភាសាបារាំងថា "សាក់ឡូ" នៅទូទាំងតំបន់ឥណ្ឌូចិន នឹងមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ។

តារាកំប្លែងសាក់ឡូ បានបន្តការដើរតួដ៏ល្បីរបស់គាត់ គឺដើរតួជា *ជនអនាថា* នៅក្នុងខ្សែភាពយន្តមានសំលេងពីរដំបូងរបស់គាត់អោយផលិតកម្ម United Artists Corporation ។
រឿងទីមួយ គឺ *ភ្លើងទីក្រុង (City Lighst)* (ឆ្នាំ១៩៣១)
និងរឿងទីពីរ គឺ *សម័យទំនើប (Modern Times)* (ឆ្នាំ១៩៣៦) ។
នៅក្នុងខ្សែភាពយន្តរឿង *សម័យទំនើប* តារាកំប្លែងសាក់ឡូ បានប្រើថ្វីគំនិតរបស់ខ្លួនចំពោះយុគសម័យថ្មី ដែលប្រើប្រាស់គ្រឿងម៉ាស៊ីនតាមរយៈការបង្កើតសាច់រឿងកំប្លែងអំពី *មនុស្ស និងគ្រឿងម៉ាស៊ីន* ដោយយកលំនាំតាមលទ្ធិរបស់កាល់ម៉ាក្ស ។ ខ្សែភាពយន្តរឿង *សម័យទំនើប* គឺជាខ្សែភាពយន្តចុងក្រោយរបស់ សាក់ឡូ គឺថារឿងពុំមានសន្ទនាទេ ប៉ុន្តែសាក់ឡូបាននិពន្ធ និងបញ្ចូល ភ្លេង និងសំលេង ។

នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៣៦ គឺ ៥ ថ្ងៃ បន្ទាប់ពីការបញ្ចាំងលើកដំបូងបំផុតនៃរឿង *សម័យទំនើប* នៅឯរោងភាពយន្ត Grauman's Chinese Theatre នៅហូលីវូដ សាក់ឡូ និងក្រុមរបស់គាត់បានធ្វើដំណើរពីប្រទេសអាមេរិកតាមនាវាឈ្មោះ SS President Coolidge មកកាន់រដ្ឋហាវ៉ៃ និងកំពង់ផែនានានៅតំបន់អាស៊ីប៉ាស៊ីហ្វិក ប៉ូឡែត ហ្គត់ដាត (Paulette Goddard) ជាតារាស្រីដ៏ឆ្នើម ដែលដើរតួជាមួយសាក់ឡូនៅក្នុងរឿង *សម័យទំនើប* បានធ្វើដំណើរជាមួយ សាក់ឡូ នៅក្នុងដំណើរទស្សនកិច្ចរយៈពេល ៥ ខែ របស់គាត់ ។ មិនយូរប៉ុន្មាន បន្ទាប់ពីការចេញដំណើររបស់ពួកគេ សេចក្តីរាយការណ៍ តាមតេឡេក្រាមបានប្រាប់ដល់ពិភពលោកទាំងមូលថា សាក់ឡូ និងប៉ូឡែត ហ្គត់ដាត បានរៀបការជាមួយគ្នានៅក្នុងប្រទេស សឹង្ហបុរី (ប្រភពផ្សេងទៀតបាននិយាយថានៅ Canton) ប៉ុន្តែ ច្រើនឆ្នាំ ក្រោយមក នៅក្នុងជីវប្រវត្តិផ្ទាល់របស់គាត់ សាក់ឡូ បានបញ្ជាក់ថា ពួកគេបានរៀបការនៅតំបន់អាស៊ី ដោយមិនបានបញ្ជាក់ថាជាប្រទេសណាមួយឡើយ ។ តាមពិតទៅ ប៉ូឡែត ហ្គត់ដាត បានធ្វើជាស្រីកំណាន់របស់ សាក់ឡូ នៅឯគេហដ្ឋានរបស់ សាក់ឡូ នៅក្នុងតំបន់ Summit Drive Beverely Hills ចាប់តាំងពីឆ្នាំ ១៩៣២ មកម្លេះ ប៉ុន្តែរឿងហេតុដែលមិនអាចពន្យល់បាន គឺសមាជិកនៃក្រុមទាំងអស់របស់គាត់ ត្រូវបានគេចុះឈ្មោះនៅក្នុងបញ្ជីអ្នកដំណើរតាមកប៉ាល់ថា មានអាសយដ្ឋាននៅ ១១០៣ ផ្លូវ Coneway, Beverley Hill រដ្ឋ កាលីហ្វ័រញ៉ាទៅវិញ ។

តាមការដកស្រង់សំដីនៅក្នុងសារពតិមាននៅពេលនោះថា ប៉ូឡែតមានអាយុ ២១ ឆ្នាំ ប៉ុន្តែតាមពិតមើលទៅ តារាស្រីរូបនេះមានអាយុប្រហែល ២៥ ឆ្នាំ ។ អ្នកយកពតិមានម្នាក់របស់សារពតិមានឥណ្ឌូចិនដែលចង់ដឹងចង់លឺ បានសួរតារាស្រីរូបនោះអំពី "ដំណឹងធំ" ចុងក្រោយ ។ អ្នកយកពតិមាននោះបានសួរថាតើ កញ្ញា ប៉ូឡែត



ហ្គត់ដាត បានក្លាយទៅជាភរិយារបស់ សាក់ឡូ ពិតមែន រឺទេ ? ប៉ូឡែត បានឆ្លើយបង្វៀង ។ តួឯកស្រីដ៏ស្រស់ស្អាតនេះ មិនបាន បដិសេធថា នាងគ្មានសិទ្ធិពាក់ចិញ្ចៀនអាពាហ៍ពិពាហ៍ធ្វើពីពេជ្រ និងប្លាទីននៅម្រាមដៃទី ៣ ខាងឆ្វេងរបស់នាងឡើយ តែនាងបែរជាអះអាងថានេះ មិនមែនមានន័យថា ស្វាមីរបស់នាងគឺជា សាក់ឡូ នោះទេ ។ នាងឈប់ឆ្លើយសំនួរផ្សេងទៀត ដោយប្រកាសថានាងមិនចង់និយាយអំពីរឿងផ្ទាល់ខ្លួនរបស់នាងជាសាធារណៈនោះទេ ។

តាមរយៈទីភ្នាក់ងាររបស់លោក Thos ក្រុមរបស់ សាក់ឡូ រួមមានតារាស្រី ប៉ូឡែត ហ្គត់ដាត ម្តាយរបស់នាងគឺលោកស្រី ហ្គត់ដាត និងជនជាតិជប៉ុនម្នាក់ឈ្មោះ Frank Yonamori ដែលជា អ្នកទទួលខុសត្រូវលើអ្នកបំរើនៅក្នុងផ្ទះ ។ តាមរយៈទីភ្នាក់ងារ Cook & Son ក្រុមរបស់សាក់ឡូ បានធ្វើដំណើរតាមកប៉ាល់ឈ្មោះ Suwa Maru ពីក្រុងសៀងហៃមកប្រទេសសឹង្ហបូរី មកដល់នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៣៦ ។ នៅថ្ងៃទី ២២ ខែ មីនា ពួកគេបាន ឆ្លងកាត់ច្រកសមុទ្រម៉ាឡាកា ដោយបានទស្សនកិច្ចកោះបាលី និងកោះហ្សាវ៉ា ហើយបន្ទាប់មក បានវិលត្រឡប់ទៅប្រទេសសឹង្ហបូរី វិញនៅថ្ងៃទី ៣

La visite à Phnom-Penh de M. Charlie Chaplin

Le populaire Charlot, en allant à Angkor, s'est arrêté à la capitale khmère où il est resté vingt quatre heures. Il est descendu au Royal Hôtel en compagnie de Mlle Paulette Godard, de Mme Godard et de son valet de chambre et secrétaire japonais.

Son temps étant limité il n'a pu nous accorder qu'un bref entretien au cours duquel il nous a fait part avec beaucoup de courtoisie et de charme, de ses impressions sur Phnompenh qu'il a visité en détail.

« La capitale cambodgienne, nous a-t-il dit, est une charmante petite ville. Le Palais Royal ainsi que la pagode d'argent, est délicieusement joli. La vie indigène a attiré son attention et les habitations cambodgiennes étaient, à son avis, très pittoresques. »

Il a opposé à nos questions sur ses prochains films le sourire bien connu du populaire Charlot et nous n'avons pas insisté.

Nous lui souhaitons ainsi qu'à ses compagnons un bon séjour et un excellent voyage au Cambodge.

*The Indochinese press barely contained their excitement over Chaplin's visit. This newspaper article (**above**), courtesy of the National Archives of Cambodia, chronicles his visit to Phnom Penh. These days, Chaplin lookalikes can turn up in the strangest of places in Cambodia. At (**left**), several lend their comic relief to a satiric Chinese opera.*

ខែ មេសា ។ នៅក្នុងប្រទេសសឹង្ហបូរី សាក់ឡូ បានស្នាក់នៅឯសណ្ឋាគារដ៏ល្បីគឺ Raffles Hotel ។

អ្នកដំណើរទាំងអស់នេះ បានមកដល់ក្រុងហូជីមិញនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៣៦ ដោយជិះកប៉ាល់ឈ្មោះ Aramis ហើយបន្ទាប់មក បានជិះរថយន្តមកកាន់ទីក្រុងភ្នំពេញ គឺពួកគេបានមកដល់សណ្ឋាគារ Le Royal នៅថ្ងៃទី ១៨ ។ នៅព្រឹកថ្ងៃ ពុធ ទី ១៩ ខែ មេសា ក្រុមនេះបានចេញដំណើរទៅកាន់ប្រាសាទអង្គរវត្ត ។

នៅពេលដែលក្រុមនេះ ទៅដល់សណ្ឋាគារ Le Royal នៅល្ងាចថ្ងៃអង្គារ អ្នកយកពត៌មានបាននាំគ្នាចោមរោមចូលទៅក្នុងសណ្ឋាគារ Le Royal ។ ដំណើរទស្សនកិច្ចរបស់ពួកគេនៅក្នុងទីក្រុងភ្នំពេញគឺមានរយៈពេលតែ ២៤ ម៉ោងប៉ុណ្ណោះ។ ក្រុមអ្នកសារពត៌មានតំណាងអោយកាសែតច្រើនជាងប្រាំនៅក្នុងតំបន់ឥណ្ឌូចិន បានយកពត៌មានពីការធ្វើដំណើររបស់ សាក់ឡូ នឹងចំណាប់អារម្មណ៍របស់គាត់ចំពោះប្រទេសកម្ពុជា ។ គាត់ទទួលរាក់ទាក់ និងរស់រាយជាមួយនឹងអ្នកយកពត៌មាននៅឯសណ្ឋាគារ ។ យើងមិនត្រឹមតែបានសំភាសន៍គាត់យ៉ាងងាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើការសន្ទនាជាមួយនឹងគាត់អស់រយៈ ពេល ២ ម៉ោង នៅតុបំរើភេសជ្ជៈទៀតផង ។

សាក់ ឡូ ត្រូវបានគេជូនដំណឹងមិនល្អនៅទីក្រុងហូជីមិញអំពីអ្វីដែលគាត់នឹងឃើញនៅក្នុងប្រទេសកម្ពុជា ដែលថាគាត់នឹងស្នាក់នៅក្នុងបន្ទប់តូចចង្អៀត នៅក្នុងដំណើរទស្សនកិច្ចរបស់គាត់ក្នុងទីក្រុងភ្នំពេញ។ ប៉ុន្តែនៅពេលដែលគាត់មកដល់ទីក្រុងភ្នំពេញ អ្វីៗផ្ទុយពីការរំពឹងទុករបស់គាត់ ។ គាត់បានមកស្នាក់នៅឯសណ្ឋាគារ Le Royal ដែលគាត់បាននិយាយសរសើរចំពោះការស្នាក់នៅរបស់គាត់នៅទីនោះ ហើយពាក្យសរសើរមួយឃ្លារបស់គាត់ថា គាត់ត្រូវបានគេទទួលអោយស្នាក់នៅសណ្ឋាគារដ៏ប្រណីតមួយ ដែលគាត់សប្បាយរីករាយនឹងសេវាបំរើដ៏អស្ចារ្យនៅទីនោះ ។

តើគាត់មានចំណាប់អារម្មណ៍ដូចម្តេចពីទីក្រុងភ្នំពេញ ? "រាជធានីរបស់ប្រទេសកម្ពុជា គឺក្រុងមួយដ៏តូចគួរអោយទាក់ចិត្តក្រៃលែង" ។ ព្រះបរមរាជវាំង និងប្រាសាទព្រះកែវមរកត គឺស្អាតណាស់ ។ គាត់មានការចាប់អារម្មណ៍ផងដែរ ចំពោះរបៀបរស់នៅរបស់ប្រជាជននៅក្នុងស្រុក ហើយបានបន្ថែមថា "ផ្ទះនៅកម្ពុជាមានភាពស្អាតវិចិត្រ" ។ គាត់គ្មានអ្វីក្រៅអំពីសំដីសរសើរ ចំពោះអាណាគមបារាំងនៅកម្ពុជា

ប៉ុន្តែគាត់មានការទិទៀនតែមួយគត់ គឺយោបល់របស់គាត់ទាក់ទងទៅនឹងស្ថាបត្យកម្មក្នុងស្រុក និយាយអោយចំទៅ គឺផ្ទះម៉ូដអឺរ៉ុបរាងពាក់កណ្តាលសង្ការ ដែលគាត់មានការភ្ញាក់ផ្អើលដោយបានឃើញគេសាងសង់តាមម៉ូដផ្ទះវីឡាតាមជាយក្រុង ដែលបង្ហាញពី (ដែលអាចចោទសួរ) ការខ្វះផាសុខភាពទូទៅ ។

នៅព្រឹកថ្ងៃដដែលនោះដែរ សាក់ឡូ បានទៅមើលព្រះបរម រាជវាំងដែលនៅទីនោះ គាត់សប្បាយចិត្ត ដោយបានឃើញព្រះបាទ ស៊ីសុវត្ថិ





*Chaplin had arrived in Phnom Penh "expecting to camp in a broom closet". Instead, he was pleasantly surprised by the hotels of Indochina (**right**) when he found himself at Hotel Le Royal where he enjoyed "perfect service".*

*This 1937 tourist brochure (**above**) describes the ruins of Angkor. Photo courtesy of l'Office Central du Tourisme Indochinois, Saigon.*

មុន្នីវង្ស ទ្រង់ប្រថាប់នៅកន្លែងដ៏សមរម្យបំផុត និងបានទៅទស្សនាប្រាសាទព្រះកែវមរកត ។ គាត់បានធ្វើដំណើរជុំវិញទីក្រុង និងមានការចាប់អារម្មណ៍ជាខ្លាំងចំពោះអ្វីដែលគាត់បានឃើញ ។ តាមសេចក្តីរាយការណ៍បាននិយាយថា សាក់ឡូ មានការស្ញើចសរសើរចំពោះទិដ្ឋភាពរស់នៅរបស់ប្រជាជននៅតាមទីក្រុងភ្នំពេញ និងដក់ចិត្តជាមួយនឹងភាពរស់រវើកពិតៗ នៅក្នុងអំឡុងពេលដែលគាត់ដើរកំសាន្តនៅកន្លែង China Town ដែលស្ថិតនៅជុំវិញម្តុំផ្សារថ្មី ដែលពេលនោះផ្សារនេះកំពុងតែសាងសង់ ។

គួរអោយចំលែកដែរ គាត់បានពន្យល់ដោយមានការភ្ញាក់ផ្អើល ថាខ្លួនគាត់ស្ថិតនៅក្នុងទីក្រុងមួយ ដែលគាត់ចាត់ទុកថារុក្ខវិថីមួយចំនួន (ពីមុនជាព្រែកជីកដែលទើបចាក់លុបថ្មីៗ) ថាស្រដៀងគ្នាទៅនឹងវិថី Champs Elysées នៅក្នុងទីក្រុងប៉ារីស ។

ក្រុមអ្នកសារពត៌មានមិនអាចអត់ទ្រាំនឹងទស្សទាយនូវខ្សែភាពយន្តមួយរបស់ សាក់ឡូ ដែលប្រហែលជានឹងត្រូវថត ដោយផ្អែកលើដំណើរទស្សនកិច្ចរបស់គាត់មកតំបន់ឥណ្ឌូចិន ។ ជាអកុសល ភាពយន្តនេះមិនដែលលេចចេញជារូបរាងឡើយ ។

មិនបាច់សង្ស័យទេ ថ្ងៃណាមួយ យើងនឹងឃើញខ្សែភាពយន្តនៅលើផ្ទាំងសំពត់សនៅតំបន់ឥណ្ឌូចិន ជាខ្សែភាពយន្តមួយដែលផុសចេញពីដំណើរទស្សនកិច្ចមកប្រទេសកម្ពុជា ដោយសិល្បៈករពូកែធ្វើត្រាប់ដ៏អស្ចារ្យនេះ ។

ទោះបីជាយ៉ាងណាក៏ដោយ យើងនឹងត្រូវតែមានភាពអត់ធ្មត់ ពីព្រោះ សាក់ឡូ មិនលាក់ខ្លួនពីយើងទេ ហើយគាត់គ្មានផែនការនឹងបោះបង់ចោលនូវវិធានការដ៏ឆ្លាតវៃ (ដែលគាត់មានអស់រយៈពេលជាច្រើនឆ្នាំ) នៃការកំណត់ខ្សែភាពយន្តរបស់គាត់តែមួយរឿងរាល់រយៈពេលប្រាំឆ្នាំ ។

អ្នកយកពត៌មានបានសួរបន្ថែមទៀតថា : ដើម្បីឆ្លើយតបទៅនឹងសំណួររបស់យើងអំពីថា តើគាត់បានមានផែនការឆ្លៀតឱកាសពីការស្នាក់នៅរបស់គាត់នៅក្នុងតំបន់ឥណ្ឌូចិន ដើម្បីចូលរួមនៅក្នុងការដើរបាញ់សត្វ រឺអត់ គាត់គ្រាន់តែប្រាប់យើងថា គាត់មិនដែលបាញ់កាំភ្លើងម្តងណាឡើយនៅក្នុងជីវិតរបស់គាត់ ហើយពុំមានបំណងចង់សំលាប់សត្វទេ សត្វដែលគាត់ចាប់អារម្មណ៍តែមួយគត់នោះ គឺដំរី ដែលគាត់មានបំណងចង់ចាប់វា តែមិនចង់សំលាប់វាទេ ។ តារាកំប្លែងដ៏អស្ចារ្យរូបនេះ បានបញ្ចប់ការសំភាសន៍របស់គាត់នៅពេលល្ងាចនោះ ដោយធ្វើការកត់សំគាល់ថា គាត់ធ្វើដំណើរដោយរថយន្តឆ្លងកាត់តំបន់ឥណ្ឌូចិន គឺបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់រូបគាត់ ដោយគាត់បានមើលទិដ្ឋភាព ថ្មីៗ ដែលគាត់មិននឹកស្មានដល់ ។ គាត់ថែមទាំងបានយល់ព្រមជួយផ្សព្វផ្សាយពាណិជ្ជកម្មអំពីទេសចរណ៍នៅក្នុងតំបន់ឥណ្ឌូចិន នៅពេលដែលគាត់ត្រឡប់ទៅប្រទេសអាមេរិកវិញទៀតផង។ ព្រឹកថ្ងៃបន្ទាប់មកក្រុមរបស់គាត់បានធ្វើដំណើរតាមរថយន្តទៅខេត្តសៀមរាប ។

លោកវិកទ័រ ហ្គោឡូប៊ូ (Victor Goloubew) (កើតឆ្នាំ ១៨៧៨ មរណភាព ១៩៤៥) ជាអភិជនមានទ្រព្យសម្បត្តិស្តុកស្តម្ភ មួយរូបមកពីទីក្រុង St Petersburg ។ គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសង្គមជាន់ខ្ពស់នៅទីក្រុងប៉ារីស (គាត់ស្គាល់វិចិត្រករ Auguste Rodin) គាត់ជាបុរាណវិទូមួយរូប ធ្វើការនៅប្រាសាទអង្គរដោយសារតែតួនាទីជា អ្នកប្រវត្តិសាស្ត្រសិល្បៈនៅឯសាលាបារាំងចុង បូពា៌ គាត់មានតួនាទីទទួលដំណើរទស្សនកិច្ចក្រុមរបស់ សាក់ឡូ ដើម្បីទស្សនាប្រាសាទអង្គរវត្តនៅខែ មេសា ឆ្នាំ ១៩៣៦ ។ ដោយសារតែពួកគេសប្បាយរីករាយនឹងការស្នាក់នៅដ៏ខ្លីនៅសណ្ឋាគារ Le Royal នៅក្នុងទីក្រុងភ្នំពេញ ពួកគេស្នាក់នៅក្នុងសណ្ឋាគារ Grand Hotel d'Angkor ស្ទើរតែទាំងស្រុង ក្នុងអំឡុងពេលស្នាក់នៅក្នុងខេត្តសៀមរាប។ បន្ទាប់ពីដំណើរទស្សនកិច្ចនៅក្នុងខេត្តសៀមរាប ក្រុមនោះបានត្រឡប់ទៅទីក្រុង ហូជីមិញវិញ ដោយឆ្លងកាត់ទីក្រុងភ្នំពេញ ដើម្បីទៅទស្សនាកន្លែងផ្សេងទៀតនៅក្នុងតំបន់ឥណ្ឌូចិន ដែលរួមទាំងទីក្រុងដាឡាត់ វ៉េ និងហាណូយ ។

នៅពេលដែលអ្នកទាំងពីរ ដែលគេសង្ស័យថាបានធ្វើដំណើរទៅក្រេបទឹកឃ្មុំ ត្រឡប់ទៅរដ្ឋកាលីហ្វ័រញ៉ាវិញនៅខែ មិថុនា ឆ្នាំ ១៩៣៦ នាងប៉ូឡែត ហ្គត់ដាត បានលេងល្បិចដាក់អ្នកយកពត៌មានម្តងទៀតដោយប្រើជំនាញដ៏ប៉ិនប្រសព្វរបស់ខ្លួន ហើយម្តងនេះនាងប្រើល្បិចជាមួយអ្នកយកពត៌មានជនជាតិអាមេរិក ។

"តើនាង និងលោក ឆាលី ឆាបលីន បានរៀបការជាមួយគ្នា រឺទេ ?"

"ប៉ុន្តែតើរឿងនេះ ពិត រឺទេ ?" ... "តើនាងបដិសេធថា នាងមិនមែនជាភរិយារបស់ សាក់ឡូ មែនទេ ?"

"ខ្ញុំមិនដែលពិភាក្សារឿងជីវិតផ្ទាល់ខ្លួនរបស់ខ្ញុំទេ ។ ខ្ញុំគិតថា ជីវិតផ្ទាល់ខ្លួនរបស់ខ្ញុំជារឿងមួយ ហើយអាជីពរបស់ខ្ញុំជារឿងមួយផ្សេងទៀត ។"

រឿងពិបាកយល់នេះ បានបន្តរហូតមកដល់សព្វថ្ងៃនេះ ។ សំនួររបស់អ្នកកាសែតទាំងអស់ ហាក់បីដូចជានៅតែមិនទាន់បានឆ្លើយនៅឡើយទេ ។ តើនាងប៉ូឡែត ហ្គត់ដាត បានរៀបការជាមួយនឹង សាក់ឡូ នៅតំបន់បូព៌ាប្រទេសមែន រឺក៏គ្រាន់តែជាការស្មាន ។ អ្នកនិពន្ធជីវប្រវត្តិគឺលោក Kenneth S. Lynn បានសរសេរនៅក្នុង សៀវភៅដែលទើបតែចេញផ្សាយថ្មីៗ មានចំណងជើងថា *សាក់ឡូ និងពេលវេលារបស់គាត់* (១៩៩៨) បង្ហាញថា "ពួកគេទំនងជាមិនបានរៀបការជាមួយគ្នាទេ ហើយថាការលែងលះគ្នា ត្រូវបានធ្វើឡើងតាមការទទូចរបស់នាង ប៉ូឡែត ហ្គត់ដាត ។ បន្ទាប់ពីមានការទាក់ទងស្នេហាច្រើនលើកមក សាក់ឡូ បានរៀបការជាមួយនឹងនាង អូអូណា GUenol (Oona O'Neil) នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៤៣ ។

សេចក្ដីបន្ថែម :

ចាប់តាំងពីពេលដែល សាក់ឡូ មកទស្សនកិច្ចតំបន់ឥណ្ឌូចិនរហូតមកដល់ឥឡូវនេះ គឺមានរយៈពេល ៦៦ ឆ្នាំហើយ ។ ដូចការផ្សាយពាណិជ្ជកម្មខ្សែភាពយន្តនៅក្នុងទសវត្សឆ្នាំ ១៩២០ និងឆ្នាំ ១៩៣០ ជាភស្តុតាងស្រាប់ គាត់ពិតជាមានប្រជាប្រិយភាពដែលគ្មាននរណាអាចប្រកួតប្រជែងបាន ។ ភាពល្បីល្បាញរបស់គាត់នៅតែមានរហូត មិនរលត់សាបសូន្យទេ ។ នៅក្នុងទសវត្សឆ្នាំ ១៩៥០ ហូ អ៊ីន ជាឈ្មោះយីហោហាងជិនួញមួយ ដែលគ្រប់គ្រងដោយជនជាតិចិន បានដាក់ផ្លាកសញ្ញាធំ ដែលមានប្រវែងស្មើហាងរបស់គាត់ផ្សព្វផ្សាយពី "ស្រាថ្នាំឱសថបុរាណសាក់ឡូ" ។ នៅក្នុងឆ្នាំ ២០០២ អ្នកលក់កាសែតវីដេអូនៅផ្សារធំថ្មីក៏មានលក់ខ្សែភាពយន្តដ៏ល្បីៗរបស់ សាក់ឡូ ផងដែរ ។

រូបភាពនៃការសំដែងជាជនអនាថារបស់ សាក់ឡូ នៅតែរស់រវើកនៅទូទៅទាំងប្រទេសកម្ពុជា ។ បច្ចុប្បន្នមានតារាកំប្លែងជនជាតិ ខ្មែរ ដែលមានប្រជាប្រិយភាពជាច្រើនរូប លាបពុកមាត់ និងលាបរង្វង់ភ្នែកពណ៌ខ្មៅ និងសក់រួញកន្ទ្រើងកន្ទ្រើង ។ លក្ខណៈទាំងអស់នេះគឺយក គំរូរីត្រាប់តាមកាយវិការរបស់សាក់ឡូ ។ គុណូបការៈរបស់ សាក់ឡូ មិនទាន់អស់ត្រឹមនេះទេ ។ វត្តមានដ៏សុសសាយរបស់គាត់ ក៏គេឃើញមាននៅក្នុងល្ខោនបាសាក់ផងដែរ ដែលនិស្សិតខ្មែរក្មេងៗសំដែងសិល្បៈរៀនផាត់ម្សៅអោយដូចមុខមាត់របស់សាក់ឡូ ។ សិល្បៈនៃការផាត់មុខនេះ ធ្វើអោយយើងនឹកឃើញខ្លាំងជាងគេដល់រឿងល្ខោនរបស់ចិន ប៉ុន្តែសិល្បៈនៃការផាត់មុខបែបនេះ ក៏ទទួលឥទ្ធិពលពីប្រភពផ្សេងៗទៀតដែរ រួមទាំងល្ខោនវៀតណាម ល្ខោនខ្មែរ ព្រមទាំងខ្សែភាពយន្ត ឥណ្ឌា និងខ្សែភាពយន្តបស្ចិមប្រទេស ។ យើងអាចបញ្ចូលឈ្មោះរបស់តារាកំប្លែងសាក់ឡូចូលក្នុងបញ្ជីនេះផងដែរ ពីព្រោះគាត់ហាក់ដូចជាបានបន្សល់ទុកនូវចំណាប់អារម្មណ៍មួយ ដែលមិនអាចលុបបំបាត់បាននៅសាលាសិល្បៈនេះ ។

នៅក្នុងប្រទេសកម្ពុជា កេរ្តិ៍ដំណែលរបស់តារាកំប្លែងនេះ នៅតែត្រូវបានគេថែរក្សាទុក ដើម្បីអោយមនុស្សជំនាន់ក្រោយៗទៀតអាចបន្តសំណើចរបស់ពួកគេ ចំពោះតួកំប្លែងដ៏គួរអោយចង់សើចបំផុត នៅលើពិភពលោក ។ តារាកំប្លែងជំនាន់បច្ចុប្បន្នរបស់កម្ពុជា ដូចជា នាយគ្រឹម នាយប៉ិតូក នាយឡោសុី និងនាយឡូតូ ត្រូវតែទទួលស្គាល់ភាពល្បីរបស់សាក់ឡូ ។

Story by Darryl Collins
Photography by Prayoon Anukarn and Bundit Arsa - ArtAsia
Billboard photography by Darryl Collins

This contemporary billboard promoting traffic safety (**below**) testifies to Chaplin's continuing popularity in present-day Cambodia.